# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ ក្រោមប្រធានបទ សិទ្ធិមនុស្សតាមទស្សនៈព្រះពុទ្ធសាសនា និងការលូតលាស់សង្គមប្រជាធិបតេយ្យសេរី ក្នុងផ្លូវអាណាចក្រ

website : www.hoksavann.org

ថ្ងៃទី២ កុម្ភៈ ២០០៦



ព្រះសម្មាសម្ពុទ្ធជាកំពូលនៃអ្នកគោរពសិទ្ធិមនុស្ស មិនតែប៉ុណ្ណោះព្រះអង្គបានណែនាំឲ្យមនុស្សគោរពសិទ្ធិនេះផង ។ លើសពីនេះទៅទៀត ព្រះអង្គបានណែនាំឲ្យគេគោរពជីវិតទូទៅ មានជីវិតសត្វតិរច្ឆានជាដើម ដូចជាធម៌បាណាក្នុងសិក្ខាបទទី១នៃសីល៥ជាដើម ។ ព្រះអង្គពន្យល់ថា មនុស្សនិងសត្វមានជីវិតមួយដូចគ្នា ស្រឡាញ់ជីវិត គឺមានជីវិតសញ្ញាដូចគ្នា ខុសគ្នាតែត្រង់គុណធម៌ប៉ុណ្ណោះ ។ ព្រះពុទ្ធបានប្រកាសប្រាប់ពិភពលោកឲ្យគោរពសិទ្ធិមនុស្សនេះកន្លងទៅជាង២៥៥០ឆ្នាំមកហើយ ចំណែកអង្គការសហប្រជាជាតិ ទើបតែប្រកាសឲ្យមនុស្សគោរពសិទ្ធិមនុស្សនៅថ្ងៃទី១០ធ្នូ១៩៤៨នេះទេ ។ អង្គការសហប្រជាជាតិបានសំរេចចាត់ទុកបុណ្យពិសាខបូជារបស់ព្រះពុទ្ធសាសនាជាបុណ្យអន្តរជាតិ ដោយព្រះពុទ្ធសាសនាកើតមុនសាសនាដទៃ ហើយព្រះពុទ្ធសាសនាបង្រៀនកុំឲ្យមនុស្សបៀតបៀនគ្នា គឺធម៌អហឹង្សា ដែលជាមូលដ្ឋាននៃសន្តិភាពពិភពលោក ។

តាមព្រះពុទ្ធសាសនា ការរំលោភសិទ្ធិមនុស្ស គឺការធ្វើឲ្យមនុស្សទទួលការឈឺចាប់ ដែលបណ្តាលមកពីការប្រព្រឹត្តពុំគប្បីពីបុគ្គលណាម្នាក់ ឬពីសំណាក់អាជ្ញាធររដ្ឋាភិបាល ។ លើសពីនេះទៀត ព្រះពុទ្ធសាសនាមិនត្រឹមតែគិតពីមារយាទមិនល្អមិនត្រឹមត្រូវរបស់បុគ្គលនិងសង្គមប៉ុណ្ណោះទេ ថែមទាំងគិតដល់ការប្រព្រឹត្តរវាងមនុស្សជាមួយសត្វតិរច្ឆាន និងរវាងមនុស្សជាមួយធម្មជាតិផងដែរ ។ សិទ្ធិប្រែថា

ផលសម្រេច គឺជាអំណាចដែលធម្មជាតិបានផ្តល់ឲ្យតាំងពីកំណើតមក ។ ពាក្យថា សិទ្ធិមនុស្ស មកពីសិទ្ធិនិងមនុស្ស ប្រែថាផលសំរេចរបស់សត្វដែលមានវិចារណញ្ញាណ បានដល់អំណាចដែលមានលទ្ធភាពអាចធ្វើឲ្យទៅជាមនុស្សពេលលក្ខណៈ ។ បានសេចក្តីថា សិទ្ធិមនុស្ស គឺជាអំណាចរបស់មនុស្ស ដែលត្រូវតែទទួលស្គាល់នូវភាពថ្លៃថ្នូរដែលជាប់ពីកំណើត និងសិទ្ធិទាំងឡាយដែលមិនអាចដកហូតបានពីមនុស្សទាំងអស់ ។ សិទ្ធិដែលមិនអាចដកហូតបាន គឺជីវិត ការនិយាយស្តី ប្រាសចាកទារុណកម្ម មិនអាចលក់ដូរ កម្មសិទ្ធិឯកជនជាដើម ។ សិទ្ធិមនុស្សជាក្របខណ្ឌច្បាប់ធម្មជាតិ និងជាគ្រឹះនៃសេរីភាព សមភាព យុត្តិធម៌ សន្តិភាព ប្រជាធិបតេយ្យ និងអភិវឌ្ឍន៍ក្នុងសង្គម និងក្នុងពិភពលោក ។

របបប្រជាធិបតេយ្យបានចាប់កំណើតឡើងតាំងពីបូរាណកាលនៅប្រទេសក្រិក ។ ប្រជាពលរដ្ឋនៃទីក្រុងអាថែននៃប្រទេសក្រិក កំពុងបានផ្លាស់ប្តូរវេនគ្នាតែងច្បាប់និងគ្រប់គ្រងភូមិស្រុករបស់ខ្លួន ។ លុះដល់ពេលក្រោយមក ប្រជាពលរដ្ឋកាន់តែមានចំនួនច្រើនឡើង ទើបគេជ្រើសរើសតំណាងឲ្យធ្វើការជំនួសវិញ ហៅថាតំណាងប្រជាពលរដ្ឋ ដោយជ្រើសរើសអ្នកមានសមត្ថភាពម្នាក់ដឹកនាំសង្គមហៅថា ប្រធានាធិបតី ។ លុះសម័យក្រោយមក គេសិក្សាយកគោលគំនិតនេះខ្លះ មកឆ្នៃរចនាលទ្ធិប្រជាធិបតេយ្យនេះឲ្យល្អប្រណិតឡើង តាមការយល់ឃើញនៃសង្គមប្រជាធិបតេយ្យសេរីរបស់ខ្លួន ។ អ្នកមានប្រជាធិបតេយ្យ គឺទទួលស្គាល់នូវកិត្តិយស នូវផលប្រយោជន៍ នូវសេរីភាពរបស់បុគ្គលម្នាក់ៗ ។ គឺសេរីភាពនេះហើយ ដែលមានលទ្ធភាពអាចសំរេចនូវទិសដៅរបស់ខ្លួនក្នុងសង្គម ។ សេរីភាពជាគន្លឹះនៃការជឿនលឿនគ្រប់វិស័យ មានវិស័យសេដ្ឋកិច្ចនិងវប្បធម៌ជាដើម នេះដោយសារអ្នកប្រជាធិបតេយ្យទទួលស្គាល់នូវសិទ្ធិរបស់បុគ្គលម្នាក់ៗ ដែលគេពុំអាចរំលោភបាន។ ការអនុវត្តន៍នៃលទ្ធិប្រជាធិបតេយ្យសេរី គឺប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោតជ្រើសរើសតំណាងប្រជាពលរដ្ឋ និងអ្នកដឹកនាំប្រទេស មានអំណាចឈរឈ្មោះឲ្យគេជ្រើសរើស មានអំណាចទិតៀននយោបាយអ្នកដឹកនាំ មានអំណាចដកហូតអ្នកដឹកនាំដែលប្រព្រឹត្តផ្ទុយអំពីប្រយោជន៍ជាតិ ។ សង្គមប្រជាធិបតេយ្យសេរីបានចែកអំណាចទាំងបីឲ្យដាច់ចេញពីគ្នា មានលក្ខណៈឯករាជ្យរៀងខ្លួន គឺអំណាចនីតិបញ្ញត្តិ បានដល់សភាជាតិនិងព្រឹទ្ធសភា អំណាចនីតិប្រតិបត្តិ បានដល់រដ្ឋាភិបាល និងអំណាចតុលាការ ដើម្បីការពារយុត្តិធម៌ ។ ឯករាជភាពរបស់តុលាការជាកត្តាសំខាន់ណាស់របស់សង្គមប្រជាធិបតេយ្យសេរី ព្រោះវាជាធាតុនៃយុត្តិធម៌ និងធ្វើឲ្យសង្គមមានស្ថេរភាព បើសង្គមគ្មានយុត្តិធម៌ទេ ជាសង្គមគ្មានលំនឹង ប្រកបដោយការចលាចល មានការរំលោភសិទ្ធិ និងបំពានច្បាប់ ។

របបកុម្មុយនិស្តពុំមានប្រជាធិបតេយ្យទេ ព្រោះរបបនេះប្រើអំណាចកាប់សម្លាប់ប្រជាពលរដ្ឋតាមអំពើចិត្ត ដោយគ្មានតុលាការជំនុំជំរះឡើយ ដកហូតសិទ្ធិសេរីភា

ពរបស់ប្រជាពលរដ្ឋ និងបង្ខំឲ្យធ្វើការដូចទាសករ ដែលគេហៅថាអំណាចផ្ដាច់ការនៃវណ្ណៈអធន ។ យើងអាចសង្ខេបជាគោលៗនៃលទ្ធិកុម្មុយនិស្តគឺ ប្រជាពលរដ្ឋគ្មានសិទ្ធិជ្រើសរើសមេដឹកនាំរបស់ខ្លួន មានគណបក្សតែមួយ គឺគណបក្សកុម្មុយនិស្ត អ្នកដឹកនាំស្ថិតនៅលើតែមនុស្សម្នាក់ ឬមនុស្សមួយក្រុមតូច ដែលហៅថាអង្គការ ឬមជ្ឈឹមបក្ស សិទ្ធិនិងសេរីភាពរបស់ប្រជាពលរដ្ឋត្រូវលុបចោលទាំងអស់ ។ ចំណែករបបផ្ដាច់ការក៏ពុំមានប្រជាធិបតេយ្យដែរ ព្រោះរបបនេះការពារអំណាចរបស់ខ្លួនដោយប្រើអាវុធ ប្រើអំពើហិង្សា ដើម្បីបំបិទមាត់ប្រជាពលរដ្ឋ និងគណបក្សណាដែលប្រឆាំងជំទាស់នឹងនយោបាយរបស់ខ្លួន ។ អំណាចតុលាការមានការលំអៀងទៅបំរើជនផ្ដាច់ការ ។ សិទ្ធិធ្វើកូដកម្មបាតុកម្មត្រូវបិទ បើហ៊ានធ្វើគេនឹងបង្ក្រាបដោយចុងកាណុង ដោយដំបងឆក់ រហូតដល់បាញ់សម្លាប់ ។ ក្រៅពីនេះ អ្នកសារពត៌មានខ្លះដែលប្រឆាំងនឹងភាពខុសឆ្គងរបស់រដ្ឋាភិបាល បានត្រូវលួចបាញ់សម្លាប់ ឬឲ្យទ្បានដេញបុក ឬក៏ចោទឡើងតុលាការ ។

តាមការសង្កេត របបកុម្មុយនិស្តនិងរបបផ្ដាច់ការ បានដួលរលំម្ដងមួយៗហើយក្នុងពិភពលោកនៅសេសសល់តិចតួច ហើយរបបផ្ដាច់ការដែលនៅសេសសល់នេះ នឹងត្រូវប្រជាពលរដ្ឋផ្ដួលរំលំជាបន្តបន្ទាប់នៅពេលខាងមុខនេះ ។ ចំណែករបបប្រជាធិបតេយ្យសេរី នឹងកាន់តែចំរើនលូតលាស់ឡើងជាលំដាប់ ។ ចំពោះប្រទេសកម្ពុជា នៅសល់ចំហាយរបបកុម្មុយនិស្តខ្លះ និងរបបផ្ដាច់ការខ្លះ ។ ទៅអនាគតយុវជននិងយុវនារីខ្មែរជឿនលឿន និងលុបបំបាត់ចោលនូវចំហាយដែលសេសសល់នេះឲ្យអស់ពីកម្ពុជា ហើយសាងរបបប្រជាធិបតេយ្យពិតប្រាកដ តាមមាគ៌ាព្រះពុទ្ធសាសនា ដែលគោរពសិទ្ធិប្រជាពលរដ្ឋជាមូលដ្ឋាន ។៚